សហភាពអឺរ៉ុប កម្មវិធីស្បៀងអាហារ

**FAO European Union Food Facility Project**

បង្កើនសន្តិសុខស្បៀងសំរាប់គ្រួសារកសិករ ដែលរងឥទ្ធិពលដោយការឡើងថ្លៃស្បៀងអាហារ

FAO EU FFP-AQ02

# ដំណើរការ និង ការថែទាំប្រព័ន្ធអាង

# បន្តាត់_ភ្ញាស់ និងបំប៉នកូនត្រីពូជ



រៀបចំដោយ : សហភាពអឺរ៉ុប កម្មវិធីស្បៀងអាហារ (GCP/CMB/033/EC)

ផ្នែកអភិវឌ្ឍន៍វារីវប្បកម្ម និង ជលផល

-ភ្នំពេញ, ខែ កក្កដា ឆ្នាំ ២០១១

# សេចក្តីថ្លែងអំណរគុណ

ឯកសារបណ្តុះបណ្តាលស្តីពី **ដំណើរការ និង ការថែទាំប្រព័ន្ធអាង បង្គាត់ ភ្ជាស់ និងបំប៉នកូនត្រីពូជ** បានរៀបចំក្រោមការឧបត្ថម្ភគាំទ្រពីកម្មវិធីស្បៀងអាហាររបស់សភាពអឺរ៉ុប (FAO EU Food Facility Project GCP/CMB/033/EC) ដែលជាលទ្ធផលនៃការប្រឹងប្រែងរួមគ្នារវាង អង្គការស្បៀង និង កសិកម្មសហប្រជាជាតិ រួមជាមួយនឹង ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ ។

សៀវភៅនេះអាចលេចចេញជារូបរាងបាន ដោយសារមានការគាំទ្របច្ចេកទេស និង សំរបសំរួលពី រដ្ឋបាលជលផល ខណ្ឌរដ្ឋបាលជលផលក្នុងខេត្តគោលដៅទាំង៥ (កំពង់ស្ពឺ តាកែវ ព្រៃវែង ស្វាយរៀង និង សៀមរាប) ទីប្រឹក្សាបច្ចេកទេសជាតិ និង អន្តរជាតិ នៃគម្រោងកម្មវិធីស្បៀងអាហាររបស់ សហភាពអឺរ៉ុប ព្រមទាំងកសិករគោលដៅរបស់គំរោង ។

សូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅចំពោះមន្ត្រី និង កសិករពាក់ព័ន្ធ ទាំងអស់ដែលបានចំណាយពេលវេលាដ៏មានតំលៃ ក្នុងការចូលរួមធ្វើអោយឯកសារនេះមានលក្ខណៈកាន់តែល្អប្រសើរ និង ឆ្លើយតបតាមតម្រូវការជាក់ស្តែង ៕

# អារម្ភកថា

សៀវភៅនេះមានឈ្មោះថា "**ដំណើរការ និងការថែទាំប្រព័ន្ធអាង បង្កាត់ ភ្ញាស់ និង បំប៉នកូនត្រីពូជ**" ដែលបានបង្កើតឡើងដោយ សហភាពអឺរ៉ុប កម្មវិធីស្បៀងអាហារ FAO European Union Food Facility Project (GCP/CMB/033/EC) សំរាប់ជាទុនមួយជួយសំរួលដល់កសិករក្នុងការផលិត និង បំប៉នកូនត្រីពូជនូវការប្រើប្រាស់ប្រព័ន្ធអាងផលិតអោយកាន់តែមានប្រសិទ្ធិផលខ្ពស់ ។

សៀវភៅនេះចែកចេញជា ៧ ផ្នែក:

- **សេចក្តីផ្តើម៖** សង្ខេបខ្លះៗពីដំណើរការប្រព័ន្ធអាង បង្កាត់ ភ្ញាស់ និង បំប៉នកូនត្រីពូជ ។ សារៈសំខាន់របស់ស្រះស្តុកទឹក សំរាប់ស្តុកទឹក កែសំរួលគុណភាពទឹក ព្រមទាំង គុណភាពដី ដែលសមស្របសំរាប់ស្រះ ។
- **បង្គុំសំណង់បំរើដល់ផលិតកម្មកូនត្រីពូជ៖** រៀបរាប់ពីបង្គុំសំណង់ និង ស្រះ សំរាប់ផលិតកម្ម កូនត្រីពូជ និង មុខងាររបស់វា ។
- **មុនពេលដំណើរការរបស់ប្រព័ន្ធ៖** រៀបរាប់អំពី ថាតើឧបករណ៍ សម្ភារៈ និង សារធាតុគីមីអ្វីខ្លះ ដែលកសិករផលិតចាំបាច់ត្រូវរៀបចំអោយស្រេចជាមុនសំរាប់ដំណើរការរបស់ផលិតកម្ម ។
- **ក្នុងពេលដំណើរការរបស់ប្រព័ន្ធ៖** គឺជាផ្នែកសំខាន់បំផុតរបស់ប្រព័ន្ធ ។ ចំនុចសំខាន់ៗ មួយចំនួនសំរាប់កសិករត្រូវ ពិនិត្យ និងតាមដាន ត្រូវបានបង្ហាញ ។
- **ការថែទាំប្រព័ន្ធ៖** វិធានការណ៍ចាំបាច់មួយចំនួនក្នុងការរក្សាគុណភាព សំណង់ និងស្រះ ត្រូវបានបង្ហាញនៅក្នុងផ្នែកនេះ ។
- **សុខភាព និង សុវត្ថិភាព៖** បង្ហាញពីចំនុចចាំបាច់ ក្នុងការថែរក្សាសុខភាព និង សុវត្ថិភាព របស់កសិករផលិតផ្ទាល់ និង អ្នកជិតខាង ព្រមទាំង ផលរបស់ផលិតកម្មកូនត្រីពូជ ។
- **គំរូប្លង់៖** ត្រូវបានភ្ជាប់ជាមួយនៅផ្នែកខាងក្រោយសៀវភៅ ដែលជាជំនួយស្មារតីដល់កសិករ ផលិតថ្មីសំរាប់យកទៅអនុវត្តន៍តាម ។

# មាតិកា


ទំព័រ

សេចក្តីថ្លែងអំណរគុណ........................................ i

អារម្ភកថា ........................................ ii

មាតិកា........................................ iii

តារាងរូបភាព........................................ iv

១. សេចក្តីផ្តើម........................................ ១

២. បង្កុំសំណង់បំរើដល់ផលិតកម្មកូនត្រីពូជ........................................ ៤

២.១ អាងស្តុកទឹក........................................ ៤

២.២ អាងបង្កាត់........................................ ៥

២.៣ អាងភ្ញាស់........................................ ៦

២.៤ អាងផ្សាំកូនត្រីម៉េ្សា........................................ ៧

២.៥ ស្រះបំប៉នកូនត្រី........................................ ៨

៣. មុនពេលដំណើរការរបស់ប្រព័ន្ធ........................................ ៩

៤. ពេលដំណើរការរបស់ប្រព័ន្ធ........................................ ១១

៤.១ អាងស្តុកទឹក........................................ ១២

៤.២ អាងបង្កាត់........................................ ១២

៤.៣ អាងភ្ញាស់........................................ ១៣

៤.៤ ការផ្សាំកូនត្រីម៉េ្សាក្នុងអាងស៊ីម៉ងត៍........................................ ១៥

៤.៥ ការបំប៉នកូនត្រីក្នុងស្រះ........................................ ១៧

៥. ការថែទាំប្រព័ន្ធ........................................ ១៨

៦. សុខភាព និង សុវត្ថិភាព........................................ ១៩

៧. គំរូប្លង់........................................ ២០

# តារាងរូបភាព

ទំព័រ


| | | |
|---|---|---|
| រូបភាព ១-១ : | ដ្យាក្រាមលំហូររបស់ប្រព័ន្ធអាងបង្កាត់ ភ្ញាស់ និង បំប៉នកូនត្រីពូជ......................... | ៣ |
| រូបភាព ២-១ : | អាងស្តុកទឹក.......................................................................................... | ៤ |
| រូបភាព ២-២: | ការរៀបចំប្រព័ន្ធបំពង់បញ្ចេញទឹកនៃអាងបង្កាត់ និង ភ្ញាស់................................. | ៥ |
| រូបភាព ២-៣ : | អាងបង្កាត់.......................................................................................... | ៦ |
| រូបភាព ២-៤ : | អាងភ្ញាស់.......................................................................................... | ៧ |
| រូបភាព ២-៥ : | អាងផ្សាំកូនត្រីម៉ែ្យវ.......................................................................................... | ៨ |
| រូបភាព ២-៦ : | ស្រះបំប៉នកូនត្រី.......................................................................................... | ៨ |
| រូបភាព ៣-១ : | ឧបករណ៍សំរាប់ផលិតកម្មកូនត្រីពូជមួយចំនួន................................................... | ៩ |
| រូបភាព ៣-២ : | ទិដ្ឋភាពទូទៅតាមដំណាក់កាលនៃប្រព័ន្ធអាងបង្កាត់ ភ្ញាស់កូនត្រីពូជ....................... | ១០ |
| រូបភាព ៣-៣ : | ការរៀបចំស្រះមុនដាក់បំប៉នកូនត្រីម៉ែ្យវ.......................................................... | ១១ |
| រូបភាព ៤-១ : | ការបំពេញទឹកក្នុងអាងស្តុកទឹក..................................................................... | ១២ |
| រូបភាព ៤-២ : | បណ្តាញបំពង់ទឹករបស់អាងបង្កាត់.................................................................. | ១៣ |
| រូបភាព ៤-៣ : | ទឹកភ្លៀងសប្បនិម្មិតនិងម៉ូទ័រខ្យល់សំរាប់អាងភ្ញាស់........................................ | ១៤ |
| រូបភាព ៤-៤ : | បណ្តាញបំពង់របស់អាងភ្ញាស់.......................................................................... | ១៥ |
| រូបភាព ៤-៥ : | អាងផ្សាំកូនត្រីម៉ែ្យវដែលមានស្បៃការពារ....................................................... | ១៦ |
| រូបភាព ៤-៦ : | អាងផ្សាំកូនត្រីម៉ែ្យវ និង ប្រព័ន្ធបំពង់បង្ហូរទឹក.................................................. | ១៧ |
| រូបភាព ៤-៧ : | ការលែងកូនត្រីទៅក្នុងស្រះ.......................................................................... | ១៧ |

## ១. សេចក្តីផ្តើម

ត្រីមានសារៈសំខាន់សំរាប់សុខភាព ។ តំរូវការត្រីសំរាប់ការហូបចុកកើនឡើងជាលំដាប់ទៅតាមការកើនឡើងនៃចំនួនប្រជាជន ។ ត្រីធម្មជាតិតែមួយមិនអាចផ្គត់ផ្គង់គ្រប់គ្រាន់ទៅតាមតំរូវការនោះឡើយ ។ ការផលិតត្រីជាការចំបាច់សំរាប់បំពេញនូវកង្វះខាតទាំងនោះ ដែលជាដំណោះស្រាយដ៍ល្អប្រសើរ ។ ការផ្ទេរចំណេះដឹងដល់កសិករពីដំណើរការផលិតកូនត្រីពូជគឺជាការចំបាច់ជួយដល់កសិករអោយមានលទ្ធភាពរកប្រាក់ចំណូលដើម្បីផ្គត់ផ្គង់ជីវភាពបាន ។ សៀវភៅនេះផ្តោតទៅលើទិដ្ឋភាពបច្ចេកទេសក្នុងការអនុវត្តន៍ និង ថែទាំ ប្រព័ន្ធអាងបង្កាត់ ភ្ញាស់ និង បំប៉នកូនត្រីពូជ ក្នុងគោលបំនងដើម្បីថែរក្សាប្រព័ន្ធអោយប្រើប្រាស់បានគង់វង្ស និង យូរអង្វែង ៕

ប្រព័ន្ធអាងផលិតនិងបំប៉នកូនត្រីពូជនេះផ្សំឡើងដោយ អាងស្តុកទឹក អាងបង្កាត់ អាងភ្ញាស់ អាងផ្សាំកូនត្រីម៉េ្យវ និង ស្រះបំប៉នកូនត្រី ។ ទឹកត្រូវបូមពីស្រះស្តុកទឹកទៅក្នុងអាងស្តុកទឹក ដែលប្រើសំរាប់ការចែកចាយបន្តដោយសេរីដល់គ្រប់អាងខាងក្រោម (រូបទី ២,៣ និងទី៤ ក្នុងរូបភាព ១-១៖ ដ្យាក្រាមលំហូររបស់ប្រព័ន្ធអាង បង្កាត់-ភ្ញាស់ និង បំប៉នកូនត្រីពូជ)។ ទឹកត្រូវបង្ហូរ ទៅអាងបង្កាត់ ដែលជា អាងសំរាប់បង្កាត់ត្រីមេបាពូជ និងប្រមូល គ្រាប់ពងត្រីដែល ជំរុះចេញពីការបង្កាត់នោះ ។ ទឹក និង ចរន្តទឹក ត្រូវផ្តល់អោយជាប់រហូតសំរាប់ការវិវត្តន៍របស់គ្រាប់ពងត្រី ។ ក្រោយពី ជំរុះពងរួចគ្រាប់ពងត្រីត្រូវបង្ហូរបន្តទៅអាងភ្ញាស់ដែលជាអាងសំរាប់ភ្ញាស់គ្រាប់ពងត្រី និងរក្សាកូនត្រីញាស់ ។ ដូចគ្នានឹងអាងបង្កាត់ដែល ចរន្តទឹកត្រូវផ្តល់អោយជាប់រហូត ។ ក្រោយ រយៈពេល ៣-៥ ថ្ងៃ កូនត្រីញាស់ត្រូវប្រមូលពីអាងភ្ញាស់ និងយកទៅផ្សាំក្នុង អាងផ្សាំកូនត្រីម៉េ្យវ រយៈពេល ២-៣ សប្តាហ៍មុននឹងយកទៅបំប៉នក្នុងស្រះបំប៉នកូនត្រី ។ ដំណើរការប្រព័ន្ធនេះធ្វើ ឡើងជាដំណាក់កាល ហើយទឹកចាំបាច់ត្រូវផ្តល់ជាប្រចាំដល់គ្រប់ដំណាក់កាលទាំងនោះ ។ ដំណើការប្រព័ន្ធត្រូវបានបង្ហាញក្នុងរូបភាព ១-១ ៕

បរិមាណទឹកមានសារៈសំខាន់សំរាប់ផ្គត់ផ្គង់ជាប្រចាំ និង គ្រប់គ្រាន់ដល់ដំណើរការផលិតកម្ម ។ ហេតុដូច្នេះ ទីតាំងប្រព័ន្ធផលិតកម្មចាំបាច់ត្រូវមានប្រភពទឹកមិនចេះរីងស្ងួត ។ ប្រភពទឹកមិនអចិន្ត្រៃយ៍ ការចិញ្ចឹមត្រីនឹងជួបបញ្ហាលំបាកយ៉ាងខ្លាំង ហើយប្រព័ន្ធទៀតសោត នឹងប្រឈមភាពបរាជ័យ ។ ប្រភពទឹកអាចជា ទឹកលើដី ទឹកក្រោមដី និង ទឹកភ្លៀង ។ ទឹកភ្លៀងមិនអាចចាត់ទុកជាប្រភពទឹកអចិន្ត្រៃយ៍បានទេ កាលណាគ្មានស្រះស្តុកទឹកដ៍ត្រឹមត្រូវ ។ ហេតុនេះស្រះស្តុកទឹកមានសារៈសំខាន់យ៉ាងខ្លាំងក្នុងការផ្តល់ទឹកសំរាប់ដំណើរការរបស់ការបង្កាត់ ភ្ញាស់ និង បំប៉នកូនត្រីពូជ៕

បរិមាណទឹកតែមួយមិនគ្រប់គ្រាន់ដើម្បីធានាដល់ការផលិតកូនត្រីពូជអោយបានល្អប្រសើរនោះទេ ។ គុណភាពទឹកគឺជារឿងសំខាន់ផងដែរ ។ ជាទូទៅ ទឹកលើដីមានភាពល្អក់ប្រែប្រួលតាមរដូវកាល ហើយសំបូរដោយកំទេចកំទីដែលជះឥទ្ធិពលដល់ការរស់នៅនិងរីកលូតលាស់របស់កូនត្រី ។

ក្នុងករណីនេះ ស្រះស្តុកទឹកអាចដើរតួជាស្រះរងកករ ដែល អាចជួយដល់ការធ្លាក់រងនៃកករ កំទេច កំទីធំៗ និង ការអណ្តែតនៃរូបធាតុស្រាលៗ ដែលអាចធ្វើអោយទឹកឡើងថ្លាមួយកំរិត ។ ជាទូទៅ ទឹកក្រោមដី ជាទឹកមានភាពថ្លា (មានភាពល្អក់កំរិតទាប និងគ្មានកំទិចកំទី) ទោះជាយ៉ាងណា ភាពរឹងនៃទឹក ជាតិដែក ជាបញ្ហាដ៏ចំបងមួយទៀត ។

សំរាប់ស្រះស្តុកទឹកនិងស្រះផ្សាំកូនត្រី គុណភាពដីក៏ជាកត្តាសំខាន់ត្រូវគិតពិចារណាថាតើដីស្រះនោះអាចស្តុកទឹកសំរាប់បំរើបំរាស់នេះបាន ឬ ទេ ។ ទឹក មិនអាចរក្សាទុកបានលើដីខ្សាច់ទេ ពីព្រោះលក្ខណៈដីខ្សាច់មានជំរាបខ្លាំង ។ ដីឥដ្ឋមានលក្ខណៈល្អសំរាប់ស្តុកទឹកបានគង់វង្ស តែដីឥដ្ឋផ្សំដោយគ្រាប់ល្អិតតូចៗដែលពិបាកនឹងរង ដែលតែងតែធ្វើអោយទឹកល្អក់ជាប្រចាំ ។ ដីឥដ្ឋល្បាយខ្សាច់ ជាដីដ៏សមរម្យសំរាប់ស្រះបំប៉នកូនត្រី និង ស្រះស្តុកទឹក ៕




**រូបភាព ១_១: ដ្យាក្រាមលំហូររបស់ប្រព័ន្ធអាង បង្កាត់_ភ្ញាស់ និង បំប៉នកូនត្រីពូជ**

# ២. បន្ទុំសំណង់បំរើដល់ផលិតកម្មកូនត្រីពូជ

## ២.១ អាងស្តុកទឹក

អាងស្តុកទឹកជាអាងប្រើសំរាប់ស្តុកទឹក និង ផ្គត់ផ្គង់ទឹកដល់ដំណើរការរបស់ អាងបង្កាត់, អាងភ្ញាស់ និង អាងបំប៉នកូនត្រីម៉េ្យ ។ បរិមាណទឹក និង សំពាធទឹកចាំបាច់ត្រូវអោយបានគ្រប់គ្រាន់ និង សមស្របសំរាប់រុញគ្រាប់ពងចេញពីអាងបង្កាត់ បង្កើតទឹកភ្លៀងសប្បនិម្មិត និង បង្កើតអោយមានចរន្តទឹកហូរ ។ អាងស្តុកទឹកគួរមានទំហំ ១៥ ម៉ែត្រគូបឡើងទៅ និង កំពស់សមស្រប ដើម្បីបង្កើនសំពាធទឹក និង ចរន្តទឹកវិល ។ បរិមាណទឹកនេះអាចជួយកាត់បន្ថយការបូមទឹកជាញឹកញាប់ពីប្រភពទឹក ព្រោះជាទូទៅបរិមាណទឹកដែលគេត្រូវប្រើប្រាស់ក្នុង ១ ថ្ងៃ មានប្រមាណ ២៤ ម៉ែត្រគូប ។ ទឹកត្រូវបានបូមយកមកពីប្រភពទឹកដោយម៉ាស៊ីនបូមទឹក ហើយបញ្ចេញទៅអាងផ្សេងៗទៀតដោយបង្ហូរតាមបណ្តាញទុយោ ។ អាងទឹកអាចមានរាង មូល, ចតុកោណកែង ឬ ការ៉េ ។ ជាទូទៅគេនិយមប្រើប្រាស់អាងរាងជាការ៉េ ។ អាងទឹកត្រូវមានបំពង់បញ្ចូលទឹក និង បញ្ចេញទឹក ព្រមទាំងបំពង់បង្ហូរកាកសំណល់សំរាប់លាងសំអាតអាង ។ ទុយោសំរាប់វាស់កំពស់ទឹកគួរត្រូវបានដាក់ភ្ជាប់ជាមួយអាងដើម្បីងាយស្រួលត្រួតពិនិត្យបរិមាណទឹកក្នុងអាង ។ រូបភាព ២-១ បង្ហាញពីប្រភេទអាងស្តុកទឹកដែលគេបានប្រើប្រាស់ ៕

|  |  |
|---|---|
| *អាងស្តុកទឹករាងជាការ៉េ* | *អាងស្តុកទឹករាងមូល* |

**រូបភាព ២_១: អាងស្តុកទឹក**

អត្ថប្រយោជន៍របស់អាងស្តុកទឹករាងជាការ៉េ ប្រៀបធៀបនឹង អាងស្តុកទឹកមូលៈ

- អាងរាងការ៉េត្រូវបានសាងសង់ជាអាងតែមួយ ចំនែក អាងមូលជាអាងធ្វើពីលូស៊ីម៉ងត៍ច្រើនតភ្ជាប់គ្នាពីមួយទៅមួយដោយទុយោដើម្បីទទួលបានបរិមាណទឹកសមស្របដូចអាងរាងការ៉េ
- ចំណាយផ្ទៃដីតូច តែមាឧទឹកបានធំ

- ការបញ្ជូនសំពាធទៅអាង បង្កាត់ ភ្ញាស់ និង បំប៉ន បានល្អជាងអាងមូល
- ការលាងសំអាតអាងរាងជាការ៉េ មានភាពងាយស្រួលជាងអាងមូល
- ការសាងសង់មានភាពងាយស្រួល

## ២.២ អាងបង្កាត់

អាងបង្កាត់គឺមានរាងមូល ឬ ជ្រុងអាស្រ័យនឹងប្រភេទពូជត្រី ។ ជាទូទៅ អាងបង្កាត់រាងមូល ច្រើនប្រើសំរាប់ពូជត្រីប្រភេទគ្រាប់ពងបណ្តែត ហើយអាងរាងជ្រុងប្រើសំរាប់ពូជត្រីគ្រាប់ពងតោង ។ អាងបង្កាត់រាងមូលក៏អាចប្រើ សំរាប់ពូជត្រីគ្រាប់ពងតោងបានដែរ ។ ភាពខុសគ្នារវាងការបង្កាត់ពូជត្រីគ្រាប់ពងបណ្តែត និង គ្រាប់ពងតោង គឺត្រង់ ការបង្កាត់ពូជត្រីគ្រាប់ពងបណ្តែតត្រូវការចរន្តទឹកវិលតែពូជត្រីគ្រាប់ពងតោង គ្រាន់តែត្រូវការផ្លាស់ទឹកក្នុងអាងអោយថ្មីជានិច្ចដែលអាចប្រើតាមរយៈទឹកភ្លៀងសប្បនិម្មិត ។ ចរន្តទឹកវិល និង ទឹកភ្លៀងសប្បនិម្មិតមានសារៈសំខាន់ក្នុងការថែរក្សាគ្រាប់ពងត្រីអោយញែកចេញពីគ្នា និង បណ្តែតខ្លួនក្នុងទឹក (សំរាប់ពូជត្រីគ្រាប់ពងបណ្តែត) ។ រាងមូលនេះមានលក្ខណៈសមស្របសំរាប់ចរន្តទឹកវិល ងាយស្រួលអោយត្រីមេបាពូជបង្កាត់គ្នា និង ជំរុះពង ។ គ្រាប់ពងទាំងនោះក្រោយពីជំរុះត្រូវបញ្ចេញទៅអាងភ្ញាស់ស្វ័យប្រវត្តិតាមប្រព័ន្ធបំពង់បង្ហូរគ្រាប់ពង ។ ជាទូទៅ អាងនេះមានអង្កត់ផ្ចិត ២,៥-៣,០ ម៉ែត្រ និង កំពស់ពី ០,៨-១,០ ម៉ែត្រ ។ ធារទឹកដែលសមស្របគឺប្រហែល ២៥ លីត្រ/នាទី ។ អាងបង្កាត់បំពាក់នូវប្រព័ន្ធបំពង់ផ្គត់ផ្គង់ទឹក (សំរាប់បង្កើតចរន្តទឹកវិល និង ទឹកភ្លៀងសប្បនិម្មិត) និង ប្រព័ន្ធបំពង់បញ្ចេញទឹក ។ បំពង់បញ្ចេញទឹកត្រូវដាក់ចំផ្ចិតអាង ដែលភ្ជាប់ជាមួយបំពង់សំរាប់រក្សាកំពស់ទឹកក្នុងអាង ដោយមិនចាំបាច់បិទការ (ព្រោះវាងាយស្រួលក្នុងការ ដក ដាក់ បំពង់ថែរក្សាកំពស់ទឹកនោះ និង សំអាតអាង) ។ បំពង់បង្ហូរគ្រាប់ពងត្រូវដាក់នៅ ចំកណ្តាលអាងក្បែរបំពង់បញ្ចេញទឹក សំរាប់បង្ហូរគ្រាប់ពងទៅក្នុងអាងភ្ញាស់ ។ គេអាចប្រើតែបំពង់បង្ហូរគ្រាប់ពង ដោយមិនចាំបាច់មានបំពង់បញ្ចេញទឹកពីអាងបង្កាត់ ។ ក្នុងករណីនេះគេប្រើបំពង់បញ្ចេញទឹករបស់អាងភ្ញាស់ជំនួសវិញ (រូបភាព ២-២) ។ ដោយសារចរន្តទឹកវិលគ្រាប់ពងត្រីទាំងអស់ត្រូវបានប្រមូល និង បង្ហូរតាមបំពង់បង្ហូរគ្រាប់ពងនោះ ។ ក្នុងពេលបង្កាត់ចរន្តទឹកវិលចាំបាច់ត្រូវរក្សាអោយមានជាប់ជានិច្ច ។ រូបភាព ២-៣ បង្ហាញពីអាងបង្កាត់ ៕




បំពង់បញ្ចេញទឹកនៃអាងបង្កាត់ និង អាងភ្ញាស់ដាច់ដោយឡែកពីគ្នា | ការប្រើបំពង់បញ្ចេញទឹករួមសំរាប់អាងបង្កាត់ និង ភ្ញាស់

**រូបភាព ២_២: ការរៀបចំប្រព័ន្ធបំពង់បញ្ចេញទឹកនៃអាងបង្កាត់ និង ភ្ញាស់**



អាងបង្កាត់



បំពង់ចរន្តទឹកវិល



បំពង់បញ្ចេញទឹក

**រូបភាព ២_៣: អាងបង្កាត់**

## ២.៣ អាងភ្ញាស់

អាងភ្ញាស់អាចប្រើជាមួយអាងបង្កាត់បាន ឬក៏សាងសង់ដាច់ដោយឡែកពីគ្នា ។ ជាទូទៅ អាងនេះ គេច្រើនសាងសង់អោយដាច់ពីអាងបង្កាត់ ដើម្បីងាយស្រួលក្នុងការគ្រប់គ្រង និង បង្កើនផលិតកម្មអោយមានប្រសិទ្ធភាព ។ អាងភ្ញាស់ គឺជាអាងសំរាប់ភ្ញាស់ពងត្រី ក្រោយពេលទំលាក់គ្រាប់ពងហើយ ៦-១២ ម៉ោង និង រក្សាកូនត្រីទើបញាស់រយៈពេល ៣-៥ ថ្ងៃ ក្រោយពេលញាស់ ។ គ្រាប់ពងនិង កូនត្រីញាស់ ត្រូវធ្វើអោយវាបណ្តែតខ្លួនក្នុងទឹកទៅតាមចរន្តទឹកវិលដែលបង្កើតឡើងពីក្បាលបំពង់បញ្ចូលទឹកមានរាងជាចំពុះទា នៅបាតអាង ឬ កណ្តាលកំពស់អាង ។ ចរន្តទឹកវិលត្រូវរក្សាអោយមានល្បឿនទឹកថេរ ២០ សង់ទីម៉ែត្រ/នាទី ។ អាងភ្ញាស់គួរមានអង្កត់ផ្ចិតពី ២,៥ ទៅ៣ ម៉ែត្រនិងមានកំពស់ពី ០,៦ ទៅ ០,៨ ម៉ែត្រ ហើយបាតអាងភ្ញាស់គួរមានកំរិតកំពស់ ទាបជាងបាតអាងបង្កាត់ដើម្បីអោយគ្រាប់ពងងាយស្រួលហូរ ។ អាងគួរតែបិតការ៉ូរលោងដើម្បីកុំអោយគ្រាប់ពង និងកូនត្រីញាស់ កកិតនឹងផ្ទៃអាងដែលមានសភាពគ្រើម ដែលអាចធ្វើអោយប៉ះពាល់ដល់គ្រាប់ពង និងកូនញាស់ ។ ប្រព័ន្ធអាងភ្ញាស់នេះត្រូវមានប្រព័ន្ធបញ្ចូល បញ្ចេញទឹកដែលមានកោះរាងមូលនៅចំកណ្តាលអាង (អង្កត់ផ្ចិត ០,៦ ម៉ែត្រ កំពស់ ០,២-០,៣ ម៉ែត្រ) រុំព័ទ្ធដោយចំរោះស្បៃមុងក្រលាញឹក (០,២ មីលីម៉ែត្រ) សំរាប់ការពារគ្រាប់ពងនិងកូនត្រីញាស់កុំអោយចេញរួច ។ កំពស់ទឹកក្នុងអាងគួរមានពី ០,៥-០,៦ ម៉ែត្រ ។ នៅតាមមាត់អាង គេអាចបំពាក់ទុយោសំរាប់បង្កើតចរន្តទឹកភ្លៀងសប្បនិម្មិត ។ ក្នុងពេល ភ្ញាស់ គេក៏អាចប្រើម៉ូទ័រខ្យល់ជំនួយផងដែរ ។ រូបភាព ២-៤ បង្ហាញពីអាងភ្ញាស់ ។




**រូបភាព ២_៤: អាងភ្ញាស់**

## ២.៤ អាងផ្សាំកូនត្រីម៉េ្យវ

អាងផ្សាំកូនត្រីម៉េ្យវគឺជាអាងសំរាប់ផ្សាំកូនត្រីម៉េ្យវដែលចេញពីអាងភ្ញាស់ ដើម្បីអោយកូនត្រីទាំងនោះស៊ាំទៅនឹងមជ្ឈដ្ឋានខាងក្រៅ កាត់បន្ថយអត្រាបាត់បង់ច្រើន មុននឹងយកទៅបំប៉នក្នុងស្រះបំប៉នកូនត្រី ។ ក្រោយពីចេញពីអាងភ្ញាស់ កូនត្រីម៉េ្យវទាំងនោះត្រូវផ្សាំក្នុងអាងចន្លោះពី ២-៣ សប្តាហ៍ មុននឹងដាក់បំប៉នក្នុងស្រះ ។ អាងផ្សាំត្រូវសាងសង់ឡើងពីស៊ីម៉ងត៍ដែលមានរាងជាចតុកោណកែង ឬការ៉េ ដែលមានទំហំជាទូទៅ ៥ x ២ x ១ ម៉ែត្រ ឬ ១០ x ៥ x ១ ម៉ែត្រ ។ អាងត្រូវមានប្រព័ន្ធទុយោសំរាប់បញ្ចូល បញ្ចេញទឹក ។ បំពង់តំណក់ទឹកភ្លៀងសប្បនិម្មិត អាចភ្ជាប់ជាមួយបំពង់បញ្ចូលទឹកប្រើសំរាប់ធ្វើអោយអាងមានទឹកថ្មីជាប់ជានិច្ច និង សំរាប់ជួយផ្តល់អុកស៊ីសែនដល់កូនត្រី ។ ប្រព័ន្ធបង្ហូរទឹក មានបំពង់បង្ហូរទឹក បំពង់សំរាប់រក្សាកំពស់ទឹកក្នុងអាង និង ស្បៃមុងក្រលាញឹករុំជុំវិញបំពង់រក្សាកំពស់ទឹកសំរាប់ការពារកុំអោយកូនត្រីហូរចេញក្រៅ ។ អាងផ្សាំកូនត្រីអាចប្រើជាអាងសំរាប់ បង្កាត់ ភ្ញាស់ ប្រភេទពូជត្រីគ្រាប់ពងតោងក៏បាន និង ស្តុកទឹកសំរាប់ប្រើប្រាស់ផ្សេងៗ ។ រូបភាពអាងផ្សាំកូនត្រីម៉េ្យវមាននៅក្នុងរូបភាពទី ២-៥ ៕




**រូបភាព ២_៥: អាងផ្សាំកូនត្រីម៉្យៅ**

## ២.៥ ស្រះបំប៉នកូនត្រី

ស្រះបំប៉នកូនត្រី ជាស្រះដែលប្រើសំរាប់បំប៉នកូនត្រីម៉្យៅដែលបានមកពីអាងផ្សាំកូនត្រីម៉្យៅ ឬ អាងភ្ញាស់ (ប្រសិនបើអាងផ្សាំមិនត្រូវបានប្រើប្រាស់) រហូតក្លាយជាកូនត្រីពូជ ។ ស្រះបំប៉នកូនត្រីត្រូវមានរាងចតុកោណព្នាយកែងដែលមានទំហំជាទូទៅ ១៥ x ១០ x ១ ម៉ែត្រ និង ជើងទេរ ០,៥ ម៉ែត្រ ។ ទំហំនេះអាចផ្ទុកកូនត្រីម៉្យៅបានពី ៥០.០០០ ទៅ ១០០.០០០ ក្បាល ។ ទោះបីយ៉ាងណាទំហំអាចប្រែប្រួលទៅតាម ពូជត្រី វដ្តផលិតកម្ម និង ស្ថានភាពជាក់ស្តែងរបស់កសិករផលិត ។ រូបភាព ២-៦ បង្ហាញពីស្រះបំប៉នកូនត្រី ៕



**រូបភាព ២_៦: ស្រះបំប៉នកូនត្រី**

## ៣. មុនពេលដំណើរការរបស់ប្រព័ន្ធ

ការរៀបចំជាការចាំបាច់មុននឹងចាប់ផ្តើមដំណើរការផលិតកូនត្រីពូជ ។ វាអាចជួយកសិករផលិតអោយចំណេញពេលវេលាក្នុងពេលអនុវត្តន៍ គ្រប់គ្រងប្រព័ន្ធបានគ្រប់ជ្រុងជ្រោយ កាត់បន្ថយទំងន់បន្ទុកការងារ និង កាត់បន្ថយការងារមិនចាំបាច់មួយចំនួនធំ ដែលអាចលើកកំពស់លទ្ធភាពផលិតកម្មមួយកំរិត ។ កសិករផលិតគួរគិតជាមុន ថាតើអ្វីខ្លះដែលនឹងត្រូវប្រើប្រាស់ក្នុងដំណើរការនោះ ហើយត្រួតពិនិត្យនូវ លក្ខណៈសំណង់ និងសំភារៈសំរាប់បំរើការងារនោះ ។ ខាងក្រោមនេះជាមុខឧបករណ៍សម្ភារៈ សំខាន់ៗដែលកសិករត្រូវត្រៀមអោយស្រេចជាមុនៈ

- ម៉ាស៊ីនបូមទឹក សាំង ឬ ម៉ាស៊ូត
- អួនអូសមេពូជ ឬ កូនត្រី និង ហាប៉ា
- ត្រីមេពូជ និង អ័រម៉ូន
- កំបោរ
- ឧបករណ៍ ឬ សម្ភារៈ សំរាប់បង្កាត់ ភ្ញាស់ និង បំប៉ន
- ជីសំរាប់ស្រះបំប៉នកូនត្រី
- ស្បៃសំរាប់គ្របអាងបង្កាត់ និង ផ្សាំកូនត្រី ការពារកុំអោយត្រីមេបាពូជលោតចេញពីអាង និងការពារសត្វល្អិតបំផ្លាញកូនត្រីម៉េ្សា
- ម៉ូទ័រខ្យល់ និង អាគុយ
- ចំណីសំរាប់កូនត្រីម៉េ្សា និងកូនត្រីពូជ
- ឧបករណ៍ និងសារធាតុគីមីសំរាប់វាស់គុណភាពទឹក
- ធុងអុកស៊ីសែន
- ឧបករណ៍បន្ទាប់បន្សំមួយចំនួនដែលចាំបាច់សំរាប់ដំណើរការផលិតកម្ម




**រូបភាព ៣_១: ឧបករណ៍សំរាប់ផលិតកម្មកូនត្រីពូជមួយចំនួន**

- ត្រួតពិនិត្យ ទឹក សំណង់ និង ប្រព័ន្ធផលិតកម្មកូនត្រី
  - ត្រួតពិនិត្យបរិមាណទឹកដែលមានថាតើអាចសមល្មមសំរាប់ដំណើរការផលិតកម្មឬទេ
  - ត្រួតពិនិត្យគុណភាពទឹក ដូចជា ប៉េហាស ស៊ីតុណ្ហភាព និងកំរិតរលាយអុកស៊ីសែនក្នុងទឹក ។ ប្រសិនបើអាច កសិករផលិតគួរត្រួតពិនិត្យនូវកំរិតរបស់ អាម៉ូញាក់ អ៊ីយ៉ុងអាម៉ូញ៉ូម អាល់កាលី ភាពរឹងរបស់ទឹក ភាពល្អក់របស់ទឹក កំហាប់ជាតិដែក ។ល។
  - ត្រួតពិនិត្យ សំណង់ ប្រព័ន្ធអាង និង ធ្វើការសាកល្បងលើដំណើរការរបស់ប្រព័ន្ធដើម្បីត្រួតពិនិត្យមើល ថាតើប្រព័ន្ធអាចដំណើរការល្អ ឬ យ៉ាងណា
    - សំណង់បិតក្នុងស្ថានភាពល្អគ្មានការប្រេះស្រាំ
    - គ្មានអ្វីរាំងស្ទះនៅក្នុងប្រព័ន្ធទុយោ និង ក្បាលបំពង់ចំពុះទា
    - គ្មានការបែកបាក់ ឬ ខូចខាតដល់ប្រព័ន្ធផ្គត់ផ្គង់បែកចែកទឹក និងប្រព័ន្ធបង្ហូរ
    - គ្រប់តំណរ វ៉ាន ស្ថិតនៅស្ថានភាពល្អ គ្មានការខូតខាត
    - ស្បៃមុងក្រលាញឹកសំរាប់ការពារ គ្រាប់ពង និង កូនត្រី មិនមានភាពធ្លុះធ្លាយ និង រុំព័ទ្ធយ៉ាងត្រឹមត្រូវទៅនឹងបំពង់បញ្ចេញទឹក
  - សំអាតគ្រប់អាង និង ប្រព័ន្ធទុយោ
  - បិទស្លាកកំណត់ចំណាំនូវមុខនាទីបែងចែកការប្រើប្រាស់ ផ្សេងគ្នារបស់ប្រព័ន្ធទុយោ
  - ជួសជុលរាល់ការខូចខាតទាំងអស់ដែលបានរកឃើញទាំងផ្នែក សំណង់និងប្រព័ន្ធ និង ដំបូលប្រក់អាង



**រូបភាព ៣_២: ទិដ្ឋភាពទូទៅតាមជំណាក់កាលនៃប្រព័ន្ធអាងបង្កាត់_ភ្ញាស់កូនត្រីពូជ**
(អាងទឹក អាងបង្កាត់ និង អាងភ្ញាស់)

- ការរៀបចំស្រះមុនពេលដាក់កូនត្រីបំប៉ន
    - ធ្វើការសំអាតស្រះដោយសំអាតស្មៅ និងប្រមូលចេញនូវរុក្ខជាតិទឹកដូចជា៖ ចក កំប្លោក និង កាកសំណល់ផ្សេងៗដែលមានក្នុងស្រះ
    - បូមទឹកពង្រីងពីស្រះ និងចាប់ត្រីស្រែ កង្កែប ក្តាម អន្ទង់ ។ល។
    - ស្តារភក់ចេញពីស្រះដោយរក្សាទុកភក់ពី ១-១,៥ ដេស៊ីម៉ែត្រ (តឹក)
    - ជួសជុលភ្លឺស្រះឡើងវិញ និង បិទគ្រប់រន្ធនៅតាមជុំវិញស្រះ
    - បាចកំបោរក្រោយសំអាតស្រះ ឬ បាចកំបោរនៅបាតស្រះក្រោយពេលជីកស្រះរួច
    - ហាលស្រះរយៈពេល ១ទៅ ២ ថ្ងៃ
    - បន្ទាប់ពីហាលស្រះរួច គេត្រូវបូមទឹកពីស្រះដែលមានពណ៌បៃតងស្រាប់ បញ្ចូលក្នុងស្រះបំប៉ន ហើយទុករយៈពេលមួយថ្ងៃមុននឹងលែងកូនត្រី ។ ទឹកនោះចាំបាច់ត្រូវច្រោះអោយស្អាត ដើម្បីដកសត្វចង្រៃកុំអោយបំផ្លាញកូនត្រី ។
    - ធ្វើរបងសំណាញ់ព័ទ្ធជុំវិញស្រះដើម្បីការពារពី សត្វទា ពស់ កណ្តុរ និង សត្វផ្សេងៗដែលអាចសំលាប់កូនត្រីបាន

|  |  |
|---|---|
| *ស្រះដែលបានសំអាតនិងបាចកំបោររួច* | *ស្រះដែលបានដាក់សំណាញ់ការពារ* |

**រូបភាព ៣_៣: ការរៀបចំស្រះមុនដាក់បំប៉នកូនត្រីម៉ៃ្យ**

## ៤. ពេលដំណើរការរបស់ប្រព័ន្ធ

ក្នុងពេលអនុវត្តន៍ កសិករផលិតត្រូវត្រួតពិនិត្យជានិច្ច និងតាមដានជាប្រចាំ លើគ្រប់អាង ស្រះ និង ប្រព័ន្ធទុយោទាំងអស់ ។ ទឹកគឺមានសារៈសំខាន់បំផុតសំរាប់ផ្គត់ផ្គង់ដល់រាល់ដំណើរការបង្កាត់ ភ្ញាស់ និង បំប៉ន ។ ការត្រួតពិនិត្យជាប្រចាំត្រូវ យកចិត្តទុកដាក់លើ៖

- បរិមាណទឹកនៅក្នុងអាងទឹក
- ចរន្តទឹកវិលនៅក្នុងអាងបង្កាត់ ភ្ញាស់ និង ប្រព័ន្ធទុយោ
- ការបែកធ្លាយបំពង់ទុយោ និង វ៉ាន
- ស្បៃមុងក្រលាញឹកដែលរុំជុំវិញបំពង់បញ្ចេញទឹក (ការធ្លុះធ្លាយ ការរុំស្ទះដោយសំណកពង)

- ត្រួតពិនិត្យរបងសំណាញ់ព័ទ្ធជុំវិញស្រះ
- ត្រួតពិនិត្យ ២ ដង/ថ្ងៃ (ព្រឹក និង ល្ងាច) នូវលក្ខណៈរបស់កូនត្រី (ការងើបឡើងមកលើផ្ទៃទឹក) ជាពិសេសពេលប្តូរចំណី និង ប្តូរទឹក

## ៤.១ អាងស្តុកទឹក

- លាងសំអាតអាងស្តុកទឹកមុនបូមទឹកបំពេញអាង
- បំពេញទឹកអោយពេញក្នុងអាង មុន និង កំពុងដំណើរការប្រព័ន្ធ
- ទឹកចាំបាច់ត្រូវតែច្រោះជាមួយនឹងស្បៃមុងក្រលាញឹក (សំរាប់ទឹកលើដី) ដើម្បីដកចេញនូវកំទេចកំទីមែកឈើ និង សត្វល្អិតមុននឹងស្តុកក្នុងអាង ។ ទឹកអាចមានភាពល្អក់សមល្មម និងមិនមានកំហាប់ជាតិដែក និង ភាពរឹងខ្ពស់ (សំខាន់សំរាប់ទឹកក្រោមដី) ។
- គ្រប់វ៉ាន់ទាំងអស់ត្រូវបិទ លើកលែងតែវ៉ានផ្គត់ផ្គង់ទឹក
- បំពេញទឹកក្នុងអាងភ្លាមៗបន្ទាប់ពីឃើញថាទឹកក្នុងអាងធ្លាក់ក្រោមកំរិតកំណត់ដែលបង្ហាញដោយទុយោសំគាល់កំរិតកំពស់ទឹក ៕




**រូបភាព ៤_១: ការបំពេញទឹកក្នុងអាងស្តុកទឹក**

## ៤.២ អាងបន្ថាត់

- ការផ្គត់ផ្គង់ទឹក
  - ទឹកចាំបាច់ជាដាច់ខាត ត្រូវផ្តល់អោយជាប្រចាំដោយគ្មានការរំខាន
  - កំនត់ការប្រើប្រាស់វ៉ានធ្វើយ៉ាងណាអោយបរិមាណទឹក និង ល្បឿនទឹកវិលថេរ
  - ត្រូវកំនត់អោយច្បាស់ថាគ្រប់បំពង់ចំពុះទា គ្មានការកកស្ទះ ហើយប្រញាប់ដកចេញភ្លាមនូវកំនកនោះប្រសិនបើវាកើតឡើង

- ការបញ្ចេញទឹក
    - ត្រូវកំនត់អោយច្បាស់ថាស្បៃមុងការពារគ្រាប់ពងត្រូវបានភ្ជាប់យ៉ាងត្រឹមត្រូវ និងគ្មានការដាច់ដោចរហែក
    - ត្រូវកំនត់អោយច្បាស់ថាវ៉ាន់របស់បំពង់បញ្ចេញទឹកត្រូវបានបើកសំរាប់រក្សាកំពស់ទឹក
    - ត្រូវកំនត់អោយច្បាស់ថាធារទឹកដែលផ្គត់អោយអាង និងធារទឹកហូរចេញស្មើគ្នា
    - ទឹកបញ្ចេញចោលគួរបញ្ចេញទៅក្នុងស្រះក្បែរនោះ
- ការបង្ហូរគ្រាប់ពង
    - គ្រាប់ពងត្រូវបង្ហូរទៅអាងភ្ញាស់តាមបំពង់បង្ហូរគ្រាប់ពង
    - បំពេញទឹកក្នុងអាងភ្ញាស់អោយបានកំពស់ស្មើនឹងកំពស់ទឹកក្នុងអាងបង្កាត់មុននឹងបង្ហូរគ្រាប់ពង
    - បើកវ៉ាន់បង្ហូរគ្រាប់ពងអោយអស់ដើម្បីកុំអោយគ្រាប់ពងហូរមានភាពបង្ខំ




**រូបភាព ៤_២: បណ្ដាញបំពង់ទឹករបស់អាងបង្កាត់**

## ៤.៣ អាងភ្ញាស់

- ការផ្គត់ផ្គង់ទឹក
    - ទឹកត្រូវបានផ្គត់ផ្គង់ដោយផ្ទាល់ពីអាងស្តុកទឹកតាមរូបភាពជាចរន្តទឹកវិល

- ល្បឿនចរន្តទឹកវិលត្រូវធ្វើអោយនៅប្រមាណ ២៥ សង់ទីម៉ែត្រ/នាទីមុននឹងគ្រាប់ពងមកដល់
- កំនត់ការប្រើប្រាស់វ៉ានធ្វើយ៉ាងណាអោយបរិមាណទឹក និង ល្បឿនទឹកវិលថេរ
- បន្ទាប់ពីពងត្រូវបានបង្ហូរអស់ហើយ ត្រូវបិទវ៉ានបង្ហូរគ្រាប់ពង ដើម្បីកុំអោយគ្រាប់ពងហូរត្រលប់ក្រោយវិញក្រោយពីបិទវ៉ានផ្គត់ផ្គង់ទឹកដល់អាងបង្កាត់
- ត្រូវកំនត់អោយច្បាស់ថាគ្រប់បំពង់ចំពុះទា គ្មានការកកស្ទះ ហើយប្រញាប់ដកចេញភ្លាមនូវកំនកនោះប្រសិនបើវាកើតឡើង
- ត្រូវបិទចរន្តទឹកនៅពេលផ្តល់ចំណីអោយកូនត្រីស៊ី (១៥-៣០ នាទី)

• **ការបញ្ចេញទឹក**

- វ៉ានបញ្ចេញទឹកត្រូវបើកជានិច្ចដើម្បីរក្សាកំពស់ទឹកក្នុងអាង
- ត្រូវកំនត់អោយច្បាស់ថាស្បៃមុងការពារកូនត្រីត្រូវបានរុំបិទយ៉ាងត្រឹមត្រូវ និងគ្មានការដាច់រហែក
- ត្រូវកំនត់អោយច្បាស់ថាបំពង់រក្សាកំពស់ទឹក ត្រូវបានភ្ជាប់យ៉ាងល្អ
- ត្រូវកំនត់អោយច្បាស់ថាធារទឹកដែលផ្តល់អោយអាង និងធារទឹកហូរចេញស្មើគ្នា
- ទឹកបញ្ចេញចោលគួរបញ្ចេញទៅក្នុងស្រះក្បែរនោះ

• **ការផ្តល់អុកស៊ីសែនបន្ថែម**

- ខ្យល់អាចបញ្ចូលក្នុងអាងដោយម៉ូទ័រខ្យល់ ដើម្បីបន្ថែមអុកស៊ីសែនទៅក្នុងទឹក ហើយជួយរុញច្រានគ្រាប់ពងត្រី និង កូនត្រីអោយបណ្តែតឡើង
- ទឹកភ្លៀងសប្បនិម្មិតអាចជួយផ្តល់អុកស៊ីសែនបន្ថែមផងដែរ



**រូបភាព ៤_៣: ទឹកភ្លៀងសប្បនិម្មិតនិងម៉ូទ័រខ្យល់សំរាប់អាងភ្ញាស់**

- ការប្រមូលកូនត្រីម៉េ្យវ
  - កូនត្រីម៉េ្យវត្រូវប្រមូលតាមបំពង់បង្ហូរកូនត្រី តាមរយៈវ៉ាន់បិទ បើក បន្ទាប់ពីរក្សាទុកអស់ប្រមាណ ៣-៥ ថ្ងៃ
  - កូនត្រីម៉េ្យវអាចប្រមូលដាក់ក្នុងធុង ឬ ថង់ផ្លាស្ទីក ដោយមានអុកសុីសែនជំនួយ




**រូបភាព ៤_៤: បណ្តាញបំពង់របស់អាងភ្ញាស់**

## ៤.៤ ការផ្សាំកូនត្រីម៉េ្យវក្នុងអាងសុីម៉ង់

- មានតែចំណីរាវតែមួយគត់ដែលត្រូវផ្តល់អោយកូនត្រីម៉េ្យវសុី
- គ្របអាងផ្សាំកូនត្រីនឹង ស្បៃមុង ការពារពីការយាយីរបស់សត្វល្អិតចង្រៃ
- ដកចេញនូវសត្វប្លង់តុង និង សត្វល្អិតផ្សេងៗទៀត



**រូបភាព ៤_៩: អាងផ្សាំកូនត្រីម៉ែ្សាដែលមានស្បៃការពារ**

- **ការផ្គត់ផ្គង់ទឹក**
  - ទឹកចាំបាច់ត្រូវបំពេញមុននឹងដាក់កូនត្រីម៉ែ្សា
  - ផ្គត់ផ្គង់ទឹកជាប់ជានិច្ចជាប្រចាំ តាមរូបភាពជាតំណក់ទឹកភ្លៀងសប្បនិម្មិត ដើម្បីធ្វើទឹកអោយថ្មីជានិច្ច និង រក្សាកំរិតអុកស៊ីសែនអោយបានល្អ
- **ការបញ្ចេញទឹក**
  - ត្រូវកំនត់អោយច្បាស់ថាបំពង់រក្សាកំពស់ទឹកនៅជាប់ជានិច្ចនឹងបំពង់បញ្ចេញទឹក
  - ត្រូវមើលស្បៃមុងការពារកូនត្រីកុំអោយរហែក និង របូតចេញពីបំពង់
  - ទឹកបញ្ចេញចោលគួរបញ្ចេញទៅក្នុងស្រះក្បែរនោះ
- **ការប្រមូលកូនត្រីម៉ែ្សា**
  - កូនត្រីម៉ែ្សាត្រូវប្រមូលតាមបំពង់បញ្ចេញទឹក ដោយគ្រាន់តែដកចេញនូវបំពង់រក្សាកំពស់ទឹក បន្ទាប់ពីកូនត្រីបំប៉នអស់ប្រមាណ ២-៣ សប្តាហ៍
  - មុននឹងប្រមូលកូនត្រី បរិមាណទឹកខ្លះត្រូវបង្ហូរចេញ ដើម្បីងាយស្រួលក្នុង ការប្រមូលផលកូនត្រី
  - កូនត្រីម៉ែ្សាអាចប្រមូលដាក់ក្នុងធុង ឬ ថង់ផ្លាស្ទិក ដោយមានអុកស៊ីសែនជំនួយ មុននឹងបញ្ជូនបន្តទៅក្នុងស្រះបំប៉នកូនត្រី




**រូបភាព ៤_៦: អាងផ្សាំកូនត្រីម៉េ្យវ និង ប្រព័ន្ធបំពង់បង្ហូរទឹក**

## ៤.៥ ការបំប៉នកូនត្រីក្នុងស្រះ

- ការលែងកូនត្រីម៉េ្យវ
  - ការលែងកូនត្រីត្រូវធ្វើក្នុងពេលត្រជាក់ នៅពេលព្រឹកចន្លោះម៉ោង ៨-១១ ម៉ោង ព្រឹក
  - កូរទឹកក្នុងស្រះដើម្បីអោយកំដៅរវាងផ្ទៃទឹកខាងលើនិងខាងក្រោមអោយមានកំដៅប្រហាក់ប្រហែលគ្នា
  - ដាក់ត្រាំថង់កូនត្រីក្នុងទឹកស្រះប្រហែលជា ១០ ទៅ ១៥ នាទី ដើម្បីអោយត្រីសាំនឹងមជ្ឈដ្ឋានថ្មី
  - បាចទឹកចូលក្នុងថង់កូនត្រីមុននឹងលែង
  - ផ្អៀងថង់កូនត្រីបន្តិចដើម្បីអោយកូនត្រីចេញបានស្រួល



*1- ការផ្សាំកូនត្រីទៅនឹងមជ្ឈដ្ឋានថ្មី*



*2- ការបាចទឹកចូលក្នុងថង់កូនត្រីម៉េ្យវ*



*3- ការលែងកូនត្រីម៉េ្យវទៅក្នុងស្រះ*

**រូបភាព ៤_៧: ការលែងកូនត្រីទៅក្នុងស្រះ** (ប្រភព: បច្ចេកទេសចិញ្ចឹមត្រីជាលក្ខណ:គ្រួសារ)

## ៥. ការថែទាំប្រព័ន្ធ

ការថែទាំជាការចាំបាច់ដែលត្រូវយកចិត្តទុកដាក់ ដើម្បីធានាដល់ការប្រើប្រាស់បានយូរអង្វែង ។

- **សំរាប់សំណង់ និង ប្រព័ន្ធ**
  - បន្ទាប់ពីដំណើរការផលិតរួច ត្រូវលាងសំអាតគ្រប់អាងទាំងអស់ ហើយត្រូវរក្សាទឹកទុកត្រាំគ្រប់អាងទាំងអស់ដើម្បីរក្សាសំនើមដល់សំណង់កុំអោយឆាប់ប្រេះស្រាំ
  - កំណត់រយៈពេលក្នុងការប្តូរទឹកចេញ និង ជំនួសទឹកថ្មីចូលកុំអោយ ទឹកស្អុយ
  - ជួសជុលគ្រប់កន្លែងប្រេះស្រាំរបស់សំណង់ប្រសិនបើមាន
  - លាងសំអាតទុយោសំរាប់មើលកំរិតកំពស់ទឹកក្នុងអាងទឹក
  - លប់ប្រព័ន្ធទុយោទឹកកុំអោយលេចចេញលើដី
  - ជួសជុលដំបូលប្រក់អាង
  - ត្រូវលាងសំអាត ពិនិត្យ និងថែទាំ ឧបករណ៍ដែលបានប្រើប្រាស់រួច
- **សំរាប់ស្រះបំប៉នកូនត្រី**
  - សំអាតស្មៅដែលដុះរញ៉េរញ៉ៃ និង រុក្ខជាតិផ្សេងៗ
  - ដាំស្មៅដើម្បីទប់ការបាក់ ហូរច្រោះជើងទេស្រះ
  - ជួសជុលរាល់ការខូចខាតរបស់ស្រះ ដូចជាបិទរន្ធធ្លុះធ្លាយ ចាក់ដីបំពេញភ្លឺស្រះ
  - ត្រួតពិនិត្យគុណភាពទឹក
  - ការផ្តល់ជីគ្រប់គ្រាន់
  - ត្រួតពិនិត្យ និង ជួសជុល រាល់របងការពារស្រះ
  - ការពារមិនអោយសត្វពាហនៈដូចជា គោ ក្របី ជ្រូក មាន់ ទា ចូលក្នុងស្រះ
  - មិនត្រូវចាក់ទឹកលាងសំភារៈដែលមានសារធាតុពុល ដូចជា សាប៊ូ ថ្នាំសំលាប់សត្វល្អិត ថ្នាំសំលាប់ស្មៅ ឬ លាងសំភារៈទាំងនោះក្នុងស្រះឡើយ
  - មិនត្រូវចោលសំរាម ក្នុងស្រះ និង ប្រមូលរាល់កាកសំណល់ដែលមានក្នុងស្រះ
  - មិនត្រូវត្រាំរុក្ខជាតិផ្សេងៗក្នុងស្រះ ដូចជា ឬស្សី កំណាត់ឈើ ស្លឹកត្នោត...
  - បើឃើញត្រីច្រើនឡើងមកផ្ទៃទឹកខាងលើក្នុងពេលព្រឹកព្រលឹមបង្ហាញថាទឹកអាចខ្វះអុកស៊ីសែន ។ ទឹកស្រះត្រូវផ្លាស់ប្តូរជាបន្ទាន់ ព្រមទាំង ផ្អាកការផ្តល់ចំណី និងដាក់ជីមួយរយៈ
  - ស្តារនិងជួសជុលស្រះបន្ទាប់ពីប្រើប្រាស់អស់ពេលពី ៣ ទៅ ៥ ឆ្នាំម្តង

## ៦. សុខភាព និង សុវត្ថិភាព

- ត្រូវទុកដាក់សារធាតុគីមីសំរាប់ត្រួតពិនិត្យទឹក អ័រម៉ូន អោយបានល្អ ដាច់ដោយឡែកពីសារធាតុដ៏ទៃ និង ឆ្ងាយពីដៃក្មេង
- ត្រូវពន្យល់ដល់ក្មេងពីផលប៉ះពាល់របស់វា និង ហាមប៉ះពាល់
- យ៉ាងហោចណាស់ត្រូវពាក់ស្រោមដៃ ម៉ាស់ និង វ៉ែនតា នៅពេលប៉ះពាល់រាល់សារធាតុគីមីទាំងនោះ
- ត្រូវលាងទឹកស្អាតភ្លាមៗ បន្ទាប់ពីមានគ្រោះថ្នាក់ជាយថាហេតុដោយសារការប៉ះពាល់ជាមួយធាតុគីមីទាំងនោះមុននឹងបញ្ជូនទៅមន្ទីរពេទ្យដែលនៅក្បែរបំផុត (ការលាងនេះគ្រាន់តែជួយកាត់បន្ថយគ្រោះថ្នាក់ខ្លះប៉ុណ្ណោះ)
- មិនត្រូវប្រើសារធាតុគីមីដែលហួសកាលបរិច្ឆេទកំណត់
- មិនត្រូវប្រើសារធាតុគីមីដើម្បីត្រួតពិនិត្យគុណភាពទឹកជិតកន្លែងផលិតកូនត្រីទេ
- មិនត្រូវទុកសារធាតុគីមីទាំងនោះនៅលើអាងណាមួយឡើយ
- សារធាតុគីមីទាំងឡាយបន្ទាប់ពីប្រើប្រាស់ហើយត្រូវបិទអោយជិត និង រក្សាទុកដាក់នៅកន្លែងដែលមានសុវត្ថិភាព
- ត្រូវមានកន្លែងទុកដាក់ធាតុគីមីទាំងនោះអោយបានសមរម្យ និង ដាក់ស្លាកសញ្ញាអោយបានច្បាស់លាស់
- មិនត្រូវចាក់ទឹកដែលបានធ្វើការពិសោធន៍រួចចូលទៅក្នុងទឹក អាង ឬ ស្រះចិញ្ចឹមត្រីឡើយ
- ត្រូវលាងដៃអោយស្អាតនឹងសាប៊ូ ឬ ផេះ ក្រោយពេលធ្វើការលើផលិតកម្មកូនត្រី ក្រោយការត្រួតពិនិត្យគុណភាពទឹក និង ក្រោយពេលធ្វើជី
- ប្រេងសាំង ឬ ប្រេងម៉ាស៊ូតត្រូវទុកអោយបានល្អ និងមិនត្រូវយកភ្លើង (ដែកកេស ទៀន ចង្កៀង) ទៅឈ្លូលមើលឡើយ (ត្រូវយកអំពូលភ្លើងអគ្គីសនី ឬ ពិល សំរាប់មើល)
- មិនត្រូវទុកទឹកក្នុងអាងនិងស្រះអោយឡើងស្អុយឡើយ និងមិនត្រូវអោយមានជ្រាំនៅជុំវិញបរិវេណអាងបង្កាត់ ភ្ញាស់ និង បំប៉នឡើយ
- ត្រូវប្រយ័ត្នជានិច្ចនៅពេលប្រើម៉ាស៊ីនបូមទឹករង្វៃដោយដៃ
- ត្រូវដកជណ្តើរចេញពីអាងទឹកនៅពេលមិនចាំបាច់ និង មិនអនុញ្ញាតអោយក្មេងឡើងលើអាង
- ត្រូវដាក់របងការពារស្រះដែលមានជំរៅជ្រៅ ដូចជាស្រះស្តុកទឹក ស្រះមេបាពូជ ដោយមានសញ្ញាប្រាប់ពីជំរៅស្រះផង ដើម្បីការពារសត្វពាហនៈនិងមនុស្ស និង មិនអនុញ្ញាតអោយក្មេងទៅក្បែរស្រះនោះទេ

# ៧. គំរូប្លង់

## ៧.១ អាងស្តុកទឹក



## ៧.២ អាងបន្លាត់

### រូបភាពមើលពីលើ




### មុខកាត់ ក-ក



## ៧.៣ អាងត្វាស់



រូបភាពមើលពីលើ
0.2m
2.5m
0.2m
បំពង់ចរន្តទឹកវិលកណ្តាលអាង
Ø25
គំណបង្រួម 40-25
បំពង់ផ្គត់ផ្គង់ទឹក
និង រ៉ូប៊ីនេ Ø40
បំពង់ចំពុះទា
Ø25
0.8m
0.6m
បំពង់ចរន្តទឹកវិលបាតអាង
Ø25
បំពង់បង្ហូរគោបំពង
Ø40
ក
ក
មុខកាត់ ក-ក
បំពង់ចំពុះទា
Ø25
បំពង់បង្ហូរកូនត្រី
បំពង់ក្បាលកំពស់ទឹក
Ø40
ស្បៃមុងក្រឡាញឹក
Ø 0.2
បំពង់បង្ហូរគ្រាប់ពង
Ø40
ឥដ្ឋការ៉ូ ១ជាន់
កំពស់ទឹក
ជញ្ជាំងការពារជ្រាបទឹក
បំពង់ចំពុះទា
រ៉ូប៊ីនេ
0.6m
ទៅអាងផ្សាំកូនត្រី ឬ
ស្រះ
បំពង់ចំពុះទា
Ø25
បំពង់បង្ហូរកូនត្រី
0.28m
0.25m
0.19m
0.15m
ទៅស្រះ
បំពង់បង្ហូរកូនត្រី
Ø40
បំពង់បញ្ចេញទឹក
Ø40
១៥ cm បេតុងក្រាលបាត
បាយអរបោត
បំពង់បង្ហូរគ្រាប់ពងពីអាងបង្កាត់

# ៧.៤ អាងផ្សាំកូនត្រីម៉្យោ



## ៧.៥ ស្រះបំប៉នកូនត្រី



ការិយាល័យគម្រោងនៅក្រុងភ្នំពេញ

អគ្គនាយកដ្ឋានកសិកម្ម

ក្រសួងកសិកម្ម រុក្ខាប្រម៉ាញ់ និង នេសាទ

ផ្ទះលេខ ៥៤ ផ្លូវ ៦៥៦ សង្កាត់ទឹកល្អក់ II ខណ្ឌទួលគោក ភ្នំពេញ កម្ពុជា

ទូរស័ព្ទ : (៨៥៥)២៣ ៩៦ ៩៥ 00 / ២៣ ២១ ៦៥ ៦៦

ទូរសារ:  (៨៥៥)២៣ ៩៦ ៩៥ 00

ការិយាល័យអង្គការស្បៀងនិងកសិកម្មនៃសហប្រជាជាតិប្រចាំកម្ពុជា

ផ្ទះលេខ ៥ ផ្លូវ ៣៧0 សង្កាត់បឹងកេងកង១  ចំការមន  ភ្នំពេញ  កម្ពុជា

ទូរស័ព្ទ     : (៨៥៥) ២៣ ២១ ១៧ 0២ / ២១ ៦៥ ៦៦

ទូរសារ     : (៨៥៥) ២៣ ២១ ៦៥ ៤៧

វែបសាយ : www.fao.org